**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩**
ក្រុមការងារចំពោះកិច្ចគ្រប់គ្រង បែងចែក និងផ្គត់ផ្គង់
ឱសថយុទ្ធសាស្ត្រសម្រាប់ប្រយុទ្ធនឹងជំងឺកូវីដ-១៩

# សេចក្តីជូនដំណឹង
# ស្តីពី
# ការចែកចាយឱសថម៉ូលណាទ្រីស (ម៉ូលនូពីរ៉ាវា កាប់ស៊ុល ២០០ មីលីក្រាម) MOLNATRIS (Molnupiravir Capsules 200mg) តាមសាខាប្រៃសណីយ៍កម្ពុជានៅតាមខេត្ត

ក្រុមការងារចំពោះកិច្ចគ្រប់គ្រង បែងចែក និងផ្គត់ផ្គង់ឱសថយុទ្ធសាស្ត្រសម្រាប់ប្រយុទ្ធនឹងជំងឺកូវីដ-១៩ សូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីបន្តចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បានទាន់ពេលវេលា និងបង្កើតបានភាពស៊ាំសហគមន៍រឹងមាំពិតប្រាកដមួយទប់ទល់នឹងជំងឺរាតត្បាតសកលកូវីដ-១៩ ក្រុមការងារបាននិងកំពុងចែកចាយឱសថម៉ូលណាទ្រីស (ម៉ូលនូពីរ៉ាវា កាប់ស៊ុល ២០០ មីលីក្រាម) MOLNATRIS (Molnupiravir Capsules 200mg) សម្រាប់ព្យាបាលជំងឺកូវីដ-១៩ ចាប់ពីកម្រិតស្រាលទៅមធ្យម ចំពោះមនុស្សពេញវ័យ នៅទីស្តីការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ ជាមួយគ្នានេះ ដើម្បីផ្តល់ភាពងាយស្រួលដល់សាធារណជនដែលរស់នៅតាមបណ្តាខេត្ត ក្រុមការងារនឹងបន្ថែមការចែកចាយឱសថម៉ូលណាទ្រីស **នៅសាខាប្រៃសណីយ៍កម្ពុជានៅតាមខេត្ត** ក្នុងតម្លៃ ៥៥ ដុល្លារអាម៉េរិក ក្នុង១ដូស (១ដូស ស្មើនឹង ១កំប៉ុង មាន ៤០គ្រាប់) **ចាប់ពីថ្ងៃពុធ ទី១៩ ខែមករា ឆ្នាំ២០២២ នេះតទៅ** ជូនមន្ទីរពេទ្យឯកជន គ្លីនិក ឱសថស្ថាន ឱសថស្ថានរង និងសាធារណជន តាមលក្ខខណ្ឌដូចខាងក្រោម៖

- បុគ្គលម្នាក់ មានសិទ្ធិបញ្ជាទិញពី៥ ដល់១០ដូស ក្នុង១ដង
- មន្ទីរពេទ្យឯកជន គ្លីនិក ឱសថស្ថាន និងឱសថស្ថានរង មានសិទ្ធិបញ្ជាទិញពី១០ ដល់២០០ដូស (ត្រូវមានលិខិតអនុញ្ញាតបើកអាជីវកម្ម) ក្នុង១ដង ហើយអាចលក់បន្តមិនលើសពី ៦៥ ដុល្លារ អាម៉េរិក ក្នុង១ដូស

ដូចនេះ មន្ទីរពេទ្យឯកជន គ្លីនិក ឱសថស្ថាន ឱសថស្ថានរង និងសាធារណជន អាចបញ្ជាទិញឱសថម៉ូលណាទ្រីស (Molnupiravir Capsules 200mg) **ដោយផ្ទាល់នៅទីស្តីការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ឬសាខាប្រៃសណីយ៍កម្ពុជានៅតាមខេត្ត (ដូចមានក្នុងតារាងព័ត៌មានលម្អិតជូនភ្ជាប់មកជាមួយ)**។ សម្រាប់ការផ្តល់មតិត្រលប់អំពីការផ្តល់សេវា ឬព័ត៌មានបន្ថែម សូមទាក់ទងទូរសព្ទលេខ ១២៣/ ០៧៧ ៨៦៧ ៩៥៧/០៩៦ ៤៦៦ ៤៦៤៦ រៀងរាល់ម៉ោងធ្វើការ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ១រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២

# ព័ត៌មានសង្ខេបអំពីឱសថម៉ូលណាទ្រីស

## ម៉ូលនូពីរ៉ាវា កាប់ស៊ុល ២០០ មីលីក្រាម

ក្រុមការងារចំពោះកិច្ចគ្រប់គ្រង បែងចែក និងផ្គត់ផ្គង់ឱសថយុទ្ធសាស្ត្រសម្រាប់ប្រយុទ្ធនឹងជំងឺកូវីដ-១៩ បាននាំចូលឱសថម៉ូលណាទ្រីស (ម៉ូលនូពីរ៉ាវា កាប់ស៊ុល ២០០ មីលីក្រាម) សម្រាប់ព្យាបាលជំងឺកូវីដ-១៩ ដែលមានព័ត៌មានសង្ខេបដូចខាងក្រោម

- បរិមាណ ១ដូស មាន ៤០គ្រាប់
- តម្លៃ ៥៥ ដុល្លារ ក្នុង១ដូស
- ការប្រើប្រាស់
  - -សម្រាប់ព្យាបាលជំងឺកូវីដ ១៩ ចាប់ពីកម្រិតស្រាលទៅមធ្យម ចំពោះមនុស្សពេញវ័យ អាយុចាប់ពី ១៨ ឆ្នាំឡើង
  - -លេបក្រោយទទួលទានអាហាររួច ឬពេលពោះទទេរ និងគួរលេបទាំងមូលជាមួយទឹកមួយកែវ ដោយមិនត្រូវបើកគ្រាប់ កិនបំបែក ឬទំពារទេ
  - -លេបម្តង ៤ គ្រាប់ (ក្នុង ១គ្រាប់មានកម្រិត ២០០ មីលីក្រាម)
  - -លេប ១ ថ្ងៃ ២ ដង (រៀងរាល់ ១២ ម៉ោងម្តង សម្រាប់រយៈពេល ៥ ថ្ងៃ)
  - -សូមពិភាក្សាជាមួយវេជ្ជបណ្ឌិត ឬឱសថការីមុនពេលប្រើឱសថម៉ូលនូពីរ៉ាវា
- សូមរក្សាឱសថនេះនៅក្នុងកំប៉ុងដើមបិទជិត នៅទីកន្លែងស្ងួតមានសីតុណ្ហភាពមិនលើស ៣០ អង្សាសេ




សម្រាប់ព័ត៌មានបន្ថែម សូមអានសេចក្តីណែនាំទូទៅស្តីពីការប្រើប្រាស់ឱសថម៉ូលណាទ្រីស (ម៉ូលនូពីរ៉ាវា កាប់ស៊ុល ២០០ មីលីក្រាម) តាម QR Code

# សេចក្តីណែនាំទូទៅស្តីពី
# ការប្រើប្រាស់ឱសថម៉ូលណាទ្រីស ( ម៉ូលនូពីរ៉ាវា កាប់ស៊ុល ២០០ មីលីក្រាម )
## MOLNATRIS™ ( Molnupiravir Capsules 200mg )

យោងវិញ្ញាបនបត្រអនុញ្ញាតប្រើប្រាស់ក្នុងលក្ខខណ្ឌបន្ទាន់ លេខ៖ ៤៨៨ សខល ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ក្រសួងសុខាភិបាល ចំពោះឱសថដែលមានចរិតលក្ខណៈដូចខាងក្រោម៖

## 1. ឈ្មោះផលិតផលឱសថ

- ឈ្មោះឱសថ៖ **ម៉ូលណាទ្រីស (ម៉ូលនូពីរ៉ាវ៉ា កាប់ស៊ុល ២០០ មីលីក្រាម)**
  **MOLNATRIS™ ( Molnupiravir Capsules 200mg )**
- ឱសថនេះគឺជាថ្នាំគ្រាប់ (Capsule) សម្រាប់លេប ដែល ១កំប៉ុង មាន ៤០គ្រាប់

## 2. រូបមន្តឱសថ

- សារធាតុសកម្ម៖ Molnupiravir 200mg
- សារធាតុរួមផ្សំ៖ Hydroxypropyl Cellulose, Microcrystalline Cellulose, Croscarmellose Sodium, Magnesium Stearate

## 3. ការប្រើប្រាស់

### 3.1. ការប្រើប្រាស់ក្នុងការព្យាបាល

Molnupiravir ប្រើសម្រាប់ព្យាបាលជំងឺឆ្លងបង្កឡើងពីវីរុសកូរូណា ២០១៩ (កូវីដ-១៩) ចាប់ពីកម្រិតស្រាលទៅមធ្យម ចំពោះមនុស្សពេញវ័យ (ចាប់ពី ១៨ឆ្នាំ ឡើងទៅ) ដែលមានលទ្ធផលតេស្តវិជ្ជមានវីរុស SARS-COV-2 និងជាពិសេសគួរប្រើចំពោះបុគ្គលដែលមានហានិភ័យក្នុងការវិវត្តទៅជាជំងឺធ្ងន់ធ្ងរ។

### 3.2. វិធីប្រើ និងកម្រិតប្រើ

- **វិធីប្រើ៖** ឱសថ Molnupiravir 200 mg ប្រើដោយលេបតាមមាត់។ គេអាចលេបឱសថនេះ ក្រោយទទួលទានអាហាររួច ឬពេលពោះទទេ និងគួរលេបទាំងមូលជាមួយទឹកមួយកែវ ដោយមិនត្រូវបើកគ្រាប់ កិនបំបែក ឬទំពាទេ។
- **កម្រិតប្រើ៖**
  - **មនុស្សពេញវ័យ៖**

កម្រិតណែនាំឱ្យប្រើនៃ Molnupiravir គឺលេបម្តង ៨០០មីលីក្រាម (ស្មើនឹងលេប ៤គ្រាប់នៃកម្រិត ២០០មីលីក្រាម) លេបរៀងរាល់ ១២ម៉ោងម្តងសម្រាប់រយៈពេល ៥ថ្ងៃ បន្តបន្ទាប់។ សុវត្ថិភាព និងប្រសិទ្ធភាពរបស់ Molnupiravir នៅពេលប្រើសម្រាប់រយៈពេលយូរជាង ៥ថ្ងៃ មិនទាន់បានសិក្សាបញ្ជាក់នៅឡើយទេ។ គួរប្រើ Molnupiravir ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីការធ្វើរោគវិនិច្ឆ័យរកឃើញជំងឺកូវីដ-១៩ និងអំឡុងពេល ៥ថ្ងៃនៃការលេចចេញរោគសញ្ញា។

*ការភ្លេចលេបឱសថ៖*

ប្រសិនបើអ្នកជំងឺភ្លេចលេប Molnupiravir ម្តង ក្នុងអំឡុងរយៈពេល ១០ម៉ោង នោះអ្នកជំងឺត្រូវលេបឱសថនេះឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន និងត្រូវបន្តកម្រិតប្រើធម្មតាតាមកាលកំណត់។ ប្រសិនបើអ្នកជំងឺភ្លេចលេបម្តងក្នុងអំឡុងរយៈពេលលើសពី ១០ម៉ោង អ្នកជំងឺមិនគួរលេបកម្រិតប្រើដែលភ្លេចនោះទេ ហើយជំនួសមកវិញត្រូវលេបកម្រិតប្រើបន្ទាប់នៅតាមពេលវេលាដែលត្រូវលេបជាធម្មតា។ អ្នកជំងឺមិនត្រូវលេបពីរដងនៃកម្រិតប្រើដើម្បីបំពេញបន្ថែមកម្រិតប្រើដែលបានភ្លេចលេបនោះទេ។

- **ក្រុមមនុស្សពិសេស៖**

**មនុស្សចាស់ជរា៖** មិនចាំបាច់មានការកែតម្រូវកម្រិតប្រើ Molnupiravir ដោយផ្អែកលើអាយុទេ ។

**អ្នកជំងឺខ្សោយមុខងារតម្រងនោម៖** មិនចាំបាច់មានការកែតម្រូវកម្រិតប្រើសម្រាប់អ្នកជំងឺខ្សោយមុខងារតម្រងនោមទេ ។

**អ្នកជំងឺខ្សោយមុខងារថ្លើម៖** មិនចាំបាច់មានការកែតម្រូវកម្រិតប្រើសម្រាប់អ្នកជំងឺខ្សោយមុខងារថ្លើមទេ។

**កុមារ៖** សុវត្ថិភាព និងប្រសិទ្ធភាពរបស់ Molnupiravir ចំពោះអ្នកជំងឺអាយុតិចជាង ១៨ឆ្នាំ មិនទាន់បានសិក្សាបញ្ជាក់នៅឡើយទេ។

## 4. ប្រតិកម្មរំខាន

យោងតាមទិន្នន័យតាមដានសិក្សាបង្ហាញថា ឱសថនេះអាចបណ្តាលឱ្យមានផលរំខានតិចតួច ដូចជា រាគ ចង្អោរ ក្អួត ធីងធោង ឈឺក្បាល និងអាចមានកន្ទួលលើស្បែក កន្ទាលត្រអាក ។ល។

## 5. ការប្រើឱសថលើសកម្រិត

មិនទាន់មានបទពិសោធន៍ក្នុងការប្រើឱសថ Molnupiravir លើសកម្រិត លើមនុស្សនៅឡើយទេ។ ក្នុងករណីប្រើ Molnupiravir លើសកម្រិត គួរតែមានការត្រួតពិនិត្យស្ថានភាពសុខភាពរបស់អ្នកជំងឺ និងអន្តរាគមន៍ផ្នែកវេជ្ជសាស្ត្របន្ទាន់តាមការចាំបាច់។ មធ្យោបាយលាងឈាមមិនត្រូវបានរំពឹងថានឹងមានលទ្ធផលក្នុងការបញ្ចេញចោលឱសថម៉ូលេគុល NHC នេះប្រកបដោយប្រសិទ្ធភាពនោះទេ។

## 6. ករណីហាមប្រើ

ហាមប្រើចំពោះអ្នកដែលងាយមានប្រតិកម្មជាមួយសារធាតុសកម្ម ឬសារធាតុរួមផ្សំណាមួយនៃឱសថ។

## 7. ករណីប្រុងប្រយ័ត្ន

សូមពិភាក្សាជាមួយវេជ្ជបណ្ឌិត ឬឱសថការីមុនពេលប្រើឱសថ Molnupiravir ។

## 8. ស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅដោះកូន

– **ស្ត្រីមានផ្ទៃពោះ៖**

ទោះបីជាមិនមានទិន្នន័យពីការប្រើ Molnupiravir លើស្ត្រីមានផ្ទៃពោះក៏ដោយ ប៉ុន្តែ ការសិក្សាលើសត្វបានបង្ហាញពីការពុលលើភាពបង្កកំណើត។ ដូច្នេះ Molnupiravir មិនត្រូវបានណែនាំឱ្យប្រើក្នុងអំឡុងពេលមានផ្ទៃពោះទេ។ ស្ត្រីដែលបម្រុងនឹងមានគភ៌គួរប្រើការពន្យារកំណើតដែលមានប្រសិទ្ធភាពសម្រាប់រយៈពេលព្យាបាល និងសម្រាប់រយៈពេល ៤ថ្ងៃបន្ទាប់ពីបញ្ចប់ការប្រើ Molnupiravir ។

# ទីតាំងចែកចាយឱសថម៉ូលណាពីរ៉ាវីស

## មន្ទីរពេទ្យ គ្លីនិក ឱសថស្ថាន ឱសថស្ថានរង និងសាធារណជន អាចបញ្ជាទិញឱសថ ម៉ូលណាពីរ៉ាវីស (Molnupiravir Capsules 200mg) គ្រប់រាជធានី- ខេត្តតាមទីតាំងដូចខាងក្រោម៖

| ទីតាំង | អាសយដ្ឋាន | លេខទូរសព្ទ |
|---|---|---|
| ទីស្តីការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | អគារលេខ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ | 123 / 077 867 957 |
| សាខាប្រៃសណីយ៍កម្ពុជា ខេត្តកណ្តាល | ផ្លូវលេខ១០៥ កែង២០៦ ភូមិ តាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ | 077 929 559 / 015 714 966 |
| សាខាប្រៃសណីយ៍កម្ពុជា ខេត្តព្រៃវែង | ភូមិ២ សង្កាត់កំពង់លាវ ក្រុងព្រៃវែង | 088 87 11 828 / 096 49 85 277 |
| សាខាប្រៃសណីយ៍កម្ពុជា ខេត្តស្វាយរៀង | ភូមិមេភ្លើង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង | 088 87 11 809 / 081 803 355 |
| សាខាប្រៃសណីយ៍កម្ពុជា ខេត្តកំពង់ឆ្នាំង | ផ្លូវជាតិលេខ៥ ភូមិ១ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង | 088 87 11 826 / 086 74 86 56 |
| សាខាប្រៃសណីយ៍កម្ពុជា ខេត្តពោធិ៍សាត់ | ផ្លូវលេខ១(រ៉បមាត់ស្ទឹង)ភូមិពាលញែក២ សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ | 088 87 11 825 / 017 503 375 |
| សាខាប្រៃសណីយ៍កម្ពុជា ខេត្តបាត់ដំបង | ផ្លូវលេខ១ ភូមិកម្មករ សង្កាត់ស្វាយប៉ោ | 088 87 11 835 / 077 846 784 |
| សាខាប្រៃសណីយ៍កម្ពុជា ខេត្តបន្ទាយមានជ័យ | ផ្លូវជាតិលេខ ៥ ភូមិ៣ សង្កាត់ ព្រះពន្លា ក្រុងសិរីសោភ័ណ | 012 818 009 / 088 87 11 829 |
| សាខាប្រៃសណីយ៍កម្ពុជា ខេត្តឧត្តរមានជ័យ | ភូមិបុរីរដ្ឋបាល សង្កាត់សំរោង ក្រុងសំរោង | 088 240 92 99 / 096 296 53 08 |
| សាខាប្រៃសណីយ៍កម្ពុជា ខេត្តសៀមរាប | វិថីពាធិកំបោរ ភូមិមណ្ឌល២ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប | 088 87 11 807 / 017 24 28 47 |
| សាខាប្រៃសណីយ៍កម្ពុជា ខេត្តកំពង់ធំ | ផ្លូវជាតិលេខ៦ ភូមិ៦ សង្កាត់កំពង់ធំ ក្រុងស្ទឹងសែន | 088 87 11 805 / 077 27 47 02 |
| សាខាប្រៃសណីយ៍កម្ពុជា ខេត្តកំពង់ស្ពឺ | ផ្លូវជាតិលេខ ៤ ភូមិសំណង់ សង្កាត់រការធំ ក្រុងច្បារមន | 088 87 11 867 / 077 274 718 |
| សាខាប្រៃសណីយ៍កម្ពុជា ខេត្តព្រះសីហនុ | វិថីឯករាជ្យ (១០០) ក្រុមទី២៧ ភូមិ៣ សង្កាត់៣ ក្រុងព្រះសីហនុ | 088 87 11 848 / 069 910 101 |
| សាខាប្រៃសណីយ៍កម្ពុជា ខេត្តកែប | ផ្លូវលេខ៣៣A ភូមិកែប សង្កាត់កែប ក្រុងកែប | 088 87 11 847 / 097 933 98 21 |
| សាខាប្រៃសណីយ៍កម្ពុជា ខេត្តកំពត | ផ្លូវលេខ៧៣៥ ភូមិ១ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត | 088 87 11 846 / 010 591 951 |
| សាខាប្រៃសណីយ៍កម្ពុជា កោះកុង | ភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ | 016 454 282 / 096 30 70 626 |
| សាខាប្រៃសណីយ៍កម្ពុជា ខេត្តតាកែវ | ផ្លូវលេខ ១៣ ភូមិ២ សង្កាត់រការក្នុង ក្រុងដូនកែវ | 088 87 11 858 / 087 742 068 |
| សាខាប្រៃសណីយ៍កម្ពុជា ខេត្តកំពង់ចាម | ផ្លូវខេមរភូមិន្ទ ភូមិ១៤ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម | 088 87 11 808 / 092 99 76 56 |
| សាខាប្រៃសណីយ៍កម្ពុជា ខេត្តត្បូងឃ្មុំ | ផ្លូវជាតិលេខ ៧ ភូមិសួងកើត សង្កាត់សួង ក្រុងសួង | 088 87 11 411 / 010 628 126 |
| សាខាប្រៃសណីយ៍កម្ពុជា ខេត្តប៉ៃលិន | ភូមិ វត្ត សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន | 088 87 11 856 / 016 974 919 |
| សាខាប្រៃសណីយ៍កម្ពុជា ខេត្តព្រះវិហារ | ផ្លូវលេខ២ ភូមិកណ្តាល សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ | 088 87 11 806 |
| សាខា ប្រៃសណីយ៍កម្ពុជា ខេត្តក្រចេះ | ផ្លូវលេខ១២ ភូមិក្រចេះ សង្កាត់ក្រចេះ ក្រុងក្រចេះ | 088 87 11 836 / 077 274 712 |
| សាខាប្រៃសណីយ៍កម្ពុជា ខេត្តស្ទឹងត្រែង | ផ្លូវ៦៣ ភូមិព្រែក សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង | 088 87 11 838 / 077 274 753 |
| សាខាប្រៃសណីយ៍កម្ពុជា ខេត្តមណ្ឌលគិរី | ភូមិដោះក្រមុំ សង្កាត់សុខដុម ក្រុងសែនមនោរម្យ | 088 87 11 865 / 011 624 118 |
| សាខាប្រៃសណីយ៍កម្ពុជា ខេត្តរតនគិរី | ផ្លូវជាតិលេខ៧៨ ភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង | 088 87 11 837 / 011 424 408 |

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងទូរសព្ទ: Hotline 123 / 077 867 957 / 096 466 4646**

– ស្ត្រីបំបៅដោះកូន៖

គេពុំទាន់បានដឹងនៅឡើយទេថាតើ Molnupiravir ឬសារធាតុផ្សំណាមួយនៃ Molnupiravir មានវត្តមាននៅក្នុងទឹកដោះមនុស្ស ឬប៉ះពាល់ដល់ការផលិតទឹកដោះមនុស្ស ឬមានឥទ្ធិពលដល់ទារកដែលបៅដោះម្ដាយនោះទេ។ ការសិក្សាជាមួយនឹង Molnupiravir លើសត្វដែលបៅដោះមិនត្រូវបានធ្វើឡើងទេ។ ដោយផ្អែកលើសក្តានុពលនៃប្រតិកម្មរំខានមកពី Molnupiravir លើកូនក្មេង ការបំបៅដោះកូនមិនត្រូវបានណែនាំទេក្នុងអំឡុងពេលព្យាបាល និងសម្រាប់រយៈពេល ៤ថ្ងៃបន្ទាប់ពីបញ្ចប់ការប្រើ Molnupiravir ។

***ភាពអាចមានកូន៖*** មិនមានឥទ្ធិពលលើភាពអាចមានកូនរបស់សត្វញី ឬឈ្មោលក្នុងការសិក្សាលើសត្វកណ្ដុរ និងមិនមានការប្រឈមចំពោះមនុស្សនៅកម្រិតដែលបានណែនាំឱ្យប្រើខាងលើ។

## 9. ប្រតិកម្មជាមួយឱសថដទៃ

មិនមានអន្តរកម្មឱសថត្រូវបានកំណត់អត្តសញ្ញាណឡើយ ដោយផ្អែកលើទិន្នន័យដែលមានតិចតួច។ មិនមានការសិក្សាគ្លីនិកនៃអន្តរកម្មឱសថត្រូវបានធ្វើឡើងជាមួយ Molnupiravir ទេ។

## 10. ដំបូន្មានក្នុងការប្រើប្រាស់ឱសថ Molnupiravir

សូមអនុវត្តតាមសេចក្តីណែនាំទូទៅ ស្តីពីការប្រើប្រាស់ឱសថម៉ូលណាទ្រីស (ម៉ូលនូពីរ៉ាវ៉ា កាប់ស៊ុល 200mg) ឱ្យបានហ្មត់ចត់។ សូមទាក់ទងទៅទូរសព្ទទាន់ហេតុការណ៍ ១២៣ ដើម្បីបញ្ជាក់ពីចំណុចដែលនៅមានចម្ងល់ ឬរាយការណ៍ពីប្រតិកម្មរំខាននានា។

## 11. ការរក្សាទុក

សូមរក្សាឱសថនេះនៅក្នុងកំប៉ុងដើមបិទជិត ទុកនៅសីតុណ្ហភាពទាបជាង ឬស្មើនឹង ៣០°C។

## 12. អាយុកាលប្រើប្រាស់

ឱសថនេះមានអាយុកាលប្រើប្រាស់ ២៤ខែ បន្ទាប់ពីកាលបរិច្ឆេទផលិត។ សូមពិនិត្យមើលថ្ងៃខែឆ្នាំផលិត និងផុតកំណត់ឱ្យបានច្បាស់មុនពេលប្រើប្រាស់។

## 13. រូបភាពប្រអប់ និងកំប៉ុងឱសថ

